ក្រសួងអប់រំ យុវជន និងកីឡា
លេខ ២៦៤៧ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រង និងការអនុវត្តកម្មវិធីអប់រំពិសេសនៅគ្រឹះស្ថានសិក្សាអប់រំពិសេសសាធារណៈ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស០១២/០៦១៨/រកម/ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
- អនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិអប់រំពិសេស
- បានឃើញប្រកាសលេខ ១១១៩ អយក.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីការគ្រប់គ្រង និងការអនុវត្តកម្មវិធីអប់រំពិសេសនៅគ្រឹះស្ថានសិក្សាអប់រំពិសេស។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

Scanned by CamScanner

**ប្រការ២ .-**

ប្រកាសនេះ មានគោលដៅកំណត់អំពី៖

- លក្ខណវិនិច្ឆ័យនៃការជ្រើសរើសគ្រូបង្រៀនអប់រំពិសេស
- ការកំណត់និយាម តួនាទី និងភារកិច្ចរបស់គ្រូបង្រៀនអប់រំពិសេស និងបុគ្គលិកមិនបង្រៀន ដែលបម្រើការងារនៅតាមគ្រឹះស្ថានអប់រំពិសេស
- រចនាសម្ព័ន្ធគ្រប់គ្រង និងការត្រួតពិនិត្យតាមដានគ្រឹះស្ថានសិក្សាអប់រំពិសេស។

**ប្រការ៣ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះកម្មវិធីអប់រំពិសេសនៅតាមវិទ្យាល័យអប់រំពិសេស វិទ្យាស្ថានជាតិអប់រំពិសេស និងថ្នាក់អប់រំពិសេសនៃគ្រឹះស្ថានសិក្សាសាធារណៈដែលស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤ .-**

ពាក្យប្រើប្រាស់ក្នុងប្រកាស នេះមាននិយមន័យកំណត់ដូចខាងក្រោម៖

- **បុគ្គលិករដ្ឋបាល** សំដៅដល់បុគ្គលិកក្របខណ្ឌរដ្ឋ ឬបុគ្គលិកកិច្ចសន្យាអប់រំពិសេស មិនបង្រៀន ដែលបម្រើការនៅតាមវិទ្យាល័យអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស
- **គ្រូបង្រៀនអប់រំពិសេស** សំដៅដល់គ្រូបង្រៀនក្របខណ្ឌរដ្ឋ ឬគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំពិសេស ដែលទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សពិការភ្នែក គថ្លង់ និងពិការសតិបញ្ញា តាមកាលវិភាគប្រចាំថ្ងៃ នៅតាមវិទ្យាល័យអប់រំពិសេស និងគ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំពិសេស
- **ឧបករណ៍ជំនួយពិសេស** សំដៅដល់ឧបករណ៍ដែលបម្រើឱ្យសិស្សពិការភ្នែក គថ្លង់ និងពិការសតិបញ្ញា ដូចជា ម៉ាស៊ីនវាស់កម្រិតនៃការស្តាប់ ឧបករណ៍វាស់កម្រិតគំហើញ ឧបករណ៍សម្រាប់សិស្សខ្សោយគំហើញ និងឧបករណ៍វាស់កុមារពិការសតិបញ្ញា
- **កម្មវិធីអប់រំពិសេស** សំដៅដល់ការផ្តល់សេវាអប់រំចំពោះអ្នកសិក្សាដែលមានតម្រូវការពិសេស ដូចជា ពិការភ្នែក គថ្លង់ និងពិការសតិបញ្ញា។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រឹះស្ថានសិក្សាអប់រំពិសេស

**ប្រការ៥ .-**

វិទ្យាល័យអប់រំពិសេស មានតួនាទីនិងភារកិច្ច ផ្តល់សេវាអប់រំដល់អ្នកមានតម្រូវការអប់រំពិសេស ដូចខាងក្រោម៖

- រៀបចំផែនការអភិវឌ្ឍវិទ្យាល័យអប់រំពិសេស និងរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានសិក្សាស្របតាមប្រភេទពិការភាព
- ទទួលសិស្សមានតម្រូវការពិសេសចូលរៀនពីកម្រិតមត្តេយ្យសិក្សារហូតដល់ថ្នាក់ទី១២
- ធ្វើយុទ្ធនាការផ្សព្វផ្សាយប្រមូលសិស្សដែលមានតម្រូវការពិសេសចូលរៀន
- សហការជាមួយអ្នកពាក់ព័ន្ធដើម្បីអភិវឌ្ឍវិទ្យាល័យអប់រំពិសេស
- សហការ និងបញ្ជូនសិស្សអប់រំពិសេស ទៅរៀននៅគ្រឹះស្ថានសិក្សាចំណេះទូទៅ ករណីខ្វះគ្រូ

២/៩

Scanned by CamScanner

- ផលិត និងគ្រប់គ្រងសម្ភារឧបទេសសម្រាប់បង្រៀន តាមតម្រូវការដល់អ្នកសិក្សាពិសេស
- គ្រប់គ្រង រៀបចំសេវាផ្តល់អាហារដល់អ្នកសិក្សា មើលថែទាំកុមារ និងពិនិត្យ តាមដានពីការស្នាក់នៅរបស់សិស្ស ការហូបអាហារ សម្លៀកបំពាក់ សម្ភារស្នាក់នៅ និងចូលរួមសម្អាតបរិស្ថានសាលាទាំងក្នុង និងក្រៅ
- សហការជាមួយមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ដើម្បីចុះពិនិត្យសុខភាពសិស្សដល់សាលា និងនាំសិស្សទៅរកសេវាសុខភាព
- ផ្តល់សេវាដឹកជញ្ជូនអ្នកសិក្សាពីផ្ទះមកសាលា និងពីសាលាទៅផ្ទះ
- ត្រួតពិនិត្យ តាមដានការផលិត និងជួសជុលឧបករណ៍ជំនួយ
- រៀបចំគ្លីបបង្រៀនភាសាសញ្ញាដល់មាតាបិតាសិស្ស ឬអ្នកអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធ
- គ្រប់គ្រងបុគ្គលិក រៀបចំកម្មវិធីសិក្សាលម្អិត បែងចែកភារកិច្ចនិងបែងចែកសេវាបង្រៀន និងចុះពិនិត្យអង្កេត តាមដាន វាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ
- គ្រប់គ្រងសិស្សអប់រំពិសេស និងត្រួតពិនិត្យកម្មវិធីសិក្សាប្រចាំឆ្នាំ និងប្រចាំខែ
- គ្រប់គ្រង និងត្រួតពិនិត្យតាមដានការប្រើប្រាស់សម្ភារៈ ឯកសាររដ្ឋបាល ឯកសារហិរញ្ញវត្ថុ ចំណូលចំណាយ និងបញ្ជីសារពើភណ្ឌ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ទទួលខុសត្រូវ និងសម្របសម្រួលការចុះពិនិត្យត្រចៀក ម៉ាស៊ីនត្រចៀក ការវាស់គំហើញសិស្សខ្សោយគំហើញ ការតាមដានកម្រិតគំហើញសិស្ស តាមដានការប្រើប្រាស់ឧបករណ៍ជំនួយ(វ៉ែនតា កែវពង្រីក ...) សម្រាប់សិស្សខ្សោយគំហើញ
- បន្តជួយដល់សិស្សពិការភ្នែក គថ្លង់ និងពិការសតិបញ្ញាដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិហេតុពួកគេបញ្ចប់ការសិក្សា និងរកការងារបានធ្វើ។

**ប្រការ៦ .-**

វិទ្យាល័យអប់រំពិសេស ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនតាមការចាំបាច់។ វិទ្យាល័យអប់រំពិសេសមានផ្នែកដូចខាងក្រោម៖

- ផ្នែករដ្ឋបាល និងគណនេយ្យ៖ ដឹកនាំ សម្របសម្រួលការងាររដ្ឋបាល ផែនការ គណនេយ្យ ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ សំណុំឯកសាររបស់សិស្ស ត្រួតពិនិត្យតាមដានការងារ និងធ្វើរបាយការណ៍
- ផ្នែកបច្ចេកទេសពិការភ្នែក៖ ដឹកនាំ សម្របសម្រួលលើការងារបង្រៀន បណ្ណាល័យ កីឡា សិល្បៈ ភាសាអង់គ្លេស កុំព្យូទ័រ ឧបករណ៍ជំនួយគំហើញ ជំនាញបង្រៀនសិស្សខ្សោយគំហើញ ជំនាញតម្រង់ទិស ដល់សិស្សពិការភ្នែក
- ផ្នែកបច្ចេកទេសគថ្លង់៖ ដឹកនាំ សម្របសម្រួលលើការងារបង្រៀន គ្រូជំនាញ បណ្ណាល័យ រោងជាង កីឡា សិល្បៈ បង្ហាត់ស្តាប់ និយាយភាសាអង់គ្លេស កុំព្យូទ័រ ឧបករណ៍ជំនួយស្តាប់ ដល់សិស្សគថ្លង់
- ផ្នែកបច្ចេកទេសពិការសតិបញ្ញា៖ ដឹកនាំ សម្របសម្រួលលើការងារបង្រៀន គ្រូជំនាញ បណ្ណាល័យ រោងជាង កីឡា សិល្បៈ បង្ហាត់ស្តាប់ និយាយភាសាអង់គ្លេស កុំព្យូទ័រ ឧបករណ៍ជំនួយ ដល់សិស្សពិការសតិបញ្ញា មានបញ្ហារៀនសូត្រ ស្របតាមប្រភេទអូទីស៊ឹម ដោនស៊ីនដ្រូម ស៊ីភី (ខូចប្រព័ន្ធចលករខួរក្បាល)។



Scanned by CamScanner

វិទ្យាល័យអប់រំពិសេសអាចមានផ្នែកផ្សេងទៀតតាមការចាំបាច់។

**ប្រការ៧ .-**

វិទ្យាស្ថានជាតិអប់រំពិសេស ត្រូវអនុវត្តតួនាទី ភារកិច្ចតាមអនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិអប់រំពិសេស និងប្រកាសលេខ ១៣៨ អយក.ប្រក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ និងការិយាល័យចំណុះវិទ្យាស្ថានជាតិអប់រំពិសេស។

## ជំពូកទី៣

## តួនាទី និងភារកិច្ចរបស់បុគ្គលិករដ្ឋបាល និងគ្រូបង្រៀន

**ប្រការ៨ .-**

បុគ្គលិករដ្ឋបាល មានតួនាទីជាសេនាធិការផ្នែករដ្ឋបាលលើការងារអប់រំពិសេសឱ្យវិទ្យាល័យអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស។

បុគ្គលិករដ្ឋបាលដែលបម្រើការងារអប់រំពិសេស ត្រូវមានភារកិច្ចដូចបុគ្គលិកអប់រំដទៃទៀត និងត្រូវមានភារកិច្ចបន្ថែមដូចខាងក្រោម៖

- ដឹកនាំនិងសម្របសម្រួលការប្រើឧបករណ៍ជំនួយពិសេស ដូចជា ម៉ាស៊ីនវាស់កម្រិតនៃការស្តាប់ ឧបករណ៍វាស់កម្រិតគំហើញ ឧបករណ៍សម្រាប់សិស្សខ្សោយគំហើញ និងឧបករណ៍វាស់កុមារពិការសតិបញ្ញា
- រៀបចំវគ្គបំប៉នសមត្ថភាពភាសាសញ្ញា និងសញ្ញាដល់អ្នកអាណាព្យាបាល និងមិត្តភក្តិសិស្ស
- ណែនាំនិងសម្របសម្រួលគ្រូបង្រៀនក្នុងការផលិតសម្ភារបង្រៀន និងរៀនដែលមានលក្ខណៈច្នៃប្រឌិតខ្ពស់សម្រាប់សិស្សពិការភ្នែក សិស្សគថ្លង់ និងពិការសតិបញ្ញា
- រៀបចំចាត់តាំងក្រុមវេនប្រចាំថ្ងៃរបស់គ្រូបង្រៀន ពិនិត្យតាមដាន និងសម្របសម្រួលការកិច្ចប្រចាំថ្ងៃរបស់បុគ្គលិក និងគ្រូបង្រៀន
- គ្រប់គ្រងទូទៅ និងគ្រប់គ្រងកុមារស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន
- មើលថែទាំ ងូតទឹក ស្លៀកពាក់ ហូបចុក ចូលគេង និងបត់ជើងតូច ធំ ក្រៅពីម៉ោងបង្រៀន
- រៀបចំបរិស្ថានសាលា ឱ្យត្រូវតាមប្រភេទពិការភាពដើម្បីឱ្យកុមារទទួលបានសេវាអប់រំពិសេស
- លើកទឹកចិត្តនិងជាទីប្រឹក្សាពិសេសពាក់ព័ន្ធនឹងពិការភាព
- ទំនាក់ទំនងជាមួយអាជ្ញាធរ សហគមន៍ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នផ្សេងៗ សម្រាប់ការប្រមូលសិស្សមានពិការភាពចូលរៀន និងគាំទ្រការអភិវឌ្ឍសេវាអប់រំពិសេស
- រៀបចំផែនការគាំទ្រសកម្មភាពបង្រៀន និងរៀនអប់រំពិសេស។

**ប្រការ៩ .-**

គ្រូបង្រៀនអប់រំពិសេស មានតួនាទីជាសេនាធិការលើការងារបង្រៀននៅវិទ្យាល័យអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស។

គ្រូបង្រៀនអប់រំពិសេសដែលបម្រើការងារអប់រំពិសេស ត្រូវមានភារកិច្ចដូចបុគ្គលិកអប់រំបង្រៀនដទៃទៀត និងត្រូវមានភារកិច្ចបន្ថែម ដូចខាងក្រោម៖



Scanned by CamScanner

- មើលថែទាំ ងូតទឹក ស្លៀកពាក់ ហូបចុក និងបត់ជើងតូច ធំ ក្នុងម៉ោងបង្រៀន
- រៀបចំខ្លឹមសារបង្រៀន និងវិធីសាស្ត្របង្រៀនទំនាក់ទំនងសរុប ដោយប្រើប្រាស់ភាសាសញ្ញា និងសញ្ញាក្នុងការបង្រៀន និងរៀន ប្រើប្រាស់វិធីពន្យល់ន័យពាក្យអរូបី ប្រើប្រាស់វេយ្យាករណ៍ភាសាខ្មែរ ខុសពីវេយ្យាករណ៍ភាសាសញ្ញា ប្រើប្រាស់វត្ថុពិត បញ្ញត្តិថ្មី និងបត់បែនតាមប្រភេទពិការភាពក្នុងថ្នាក់នីមួយៗ
- ប្រមូលសិស្សចូលរៀនវិញក្រោយពីចេញលេង
- ត្រួតពិនិត្យ ជួសជុលឧបករណ៍ជំនួយការស្តាប់ និងឧបករណ៍ជំនួយការមើលជាប្រចាំ
- ត្រួតពិនិត្យតាមដានសេវាសុខភាព បញ្ជូនសិស្សទៅមន្ទីរពេទ្យតាមប្រភេទពិការ និងតាមថែទាំបកប្រែ
- បង្រៀនវិធីសាស្ត្រសម្រាប់នាំផ្លូវជនពិការភ្នែក
- ចូលរួមគ្រប់សកម្មភាពក្នុងការពិនិត្យត្រចៀក ពិនិត្យគំហើញ ជាមួយគ្រូពេទ្យជំនាញ
- បង្រៀនភាសាសញ្ញាដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សដើម្បីជួយជំរុញការងាររៀនសូត្រនៅផ្ទះ
- បង្កើតសម្ភារឧបទេស និម្មិតសញ្ញា និងសម្ភារផុសសម្រាប់បង្រៀន និងរៀន
- បង្រៀនពីប្រមាណវិធីដើម្បីគណនាលើក្បាច់
- បង្រៀនអក្សរប្រៃយ៍ (អក្សរស្ទាប) នៅលើស្លេត និងស្ទ្លៃឡាស់
- បង្រៀនសិស្សខ្សោយគំហើញដោយប្រើអក្សរធំៗ រូបភាពជិត និងក្លារទម្រ
- បកប្រែភាសាសញ្ញាដល់ជនគថ្លង់ដែលមានធុរៈ ប្រឡងសញ្ញាបត្រ និងពិធីផ្សេងៗ។

ដោយឡែកគ្រូបង្រៀននៅវិទ្យាស្ថានជាតិអប់រំពិសេស ត្រូវអនុវត្តភារកិច្ចខាងលើ និងអនុវត្តនូវភារកិច្ចបន្ថែមដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ ពីតម្រូវការរបស់អ្នកសិក្សាដែលមានតម្រូវការពិសេស
- ស្រាវជ្រាវ និងផលិតសៀវភៅភាសាសញ្ញា អក្សរប្រៃយ៍ ថតអត្ថបទជាសំឡេងសម្រាប់អ្នកសិក្សាពិការភ្នែក និងថតវីដេអូជាសញ្ញាសម្រាប់អ្នកសិក្សាគថ្លង់
- រៀបចំកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនអប់រំពិសេស
- អនុវត្តភារកិច្ចតាមលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន។

## ជំពូកទី៤
## លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស

**ប្រការ១០.-**

វិទ្យាស្ថានជាតិអប់រំពិសេសត្រូវបណ្តុះបណ្តាលគ្រូ និងធ្វើវិក្រឹតការគ្រូបង្រៀន សម្រាប់លើកកម្ពស់ការអប់រំ ការគ្រប់គ្រង និងការអនុវត្តកម្មវិធីអប់រំពិសេសនៅគ្រឹះស្ថានសិក្សាអប់រំពិសេស ឱ្យមានប្រសិទ្ធភាពខ្ពស់ គុណភាព សមធម៌ និងបរិយាបន្ន។

ការជ្រើសរើសបេក្ខជនចូលបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំពិសេស ត្រូវអនុវត្តដូចការជ្រើសរើសគ្រូបង្រៀនក្នុងប្រព័ន្ធចំណោះទូទៅ និងត្រូវមានលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យបន្ថែមដូចខាងក្រោម៖



Scanned by CamScanner

- សញ្ញាបត្រកម្រិតមធ្យមសិក្សាទុតិយភូមិឡើង សម្រាប់របមន្តបណ្តុះបណ្តាល(១២+២) និង (១២+៤) ឬមានសញ្ញាបត្រផ្នែកអប់រំពិសេស ឬជំនាញអប់រំកុមារពិការ ឬសញ្ញាបត្រគរុកោសល្យអប់រំពិសេស សម្រាប់របមន្តបណ្តុះបណ្តាល (បរិញ្ញាបត្រ+១)
- មានចំណេះដឹងផ្នែកអប់រំពិសេស ឬឧបនិស្ស័យផ្នែកអប់រំពិសេស ឬមានចំណេះដឹងអំពីការប្រើប្រាស់ឧបករណ៍ជំនួយ ការកំណត់អត្តសញ្ញាណកុមារពិការ
- មានភាពអំណត់ ព្យាយាម ទំនាក់ទំនងល្អ រួសរាយរាក់ទាក់ លើកទឹកចិត្ត ចូលរួមសកម្មភាពសង្គម។

**ប្រការ១១ ._**

ការជ្រើសរើសចូលធ្វើវិក្រឹតការនៅវិទ្យាស្ថានជាតិអប់រំពិសេស ត្រូវអនុវត្តតាមលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

- មានជំនាញផ្នែកអប់រំពិសេស ដូចជាភាសាសញ្ញា អក្សរប្រេយ៍ និងផ្នែកសតិបញ្ញា
- មានបទពិសោធការងារជាមួយកុមារពិការ
- មានចំណេះដឹងផ្នែកអប់រំពិសេស
- មានសញ្ញាបត្រផ្នែកអប់រំពិសេស ឬជំនាញអប់រំកុមារពិការ
- មានសញ្ញាបត្រគរុកោសល្យ ឬមានសញ្ញាបត្រតាមកម្រិតនៃការជ្រើសរើស
- មានទំនាក់ទំនងល្អ រួសរាយរាក់ទាក់
- មានភាពអំណត់ ព្យាយាម លើកទឹកចិត្ត ចូលរួមសកម្មភាពសង្គម
- មានចំណេះដឹងអំពីការប្រើប្រាស់ឧបករណ៍ជំនួយ ការកំណត់អត្តសញ្ញាណកុមារពិការ
- មានចំណេះដឹងអំពីកម្មវិធីសិក្សា និងប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជា
- មានចំណេះដឹងអំពីការផលិត និងការប្រើប្រាស់សម្ភារសិក្សាសម្រាប់សិស្សពិការ
- មានអតីតភាពការងារចាប់ពីពីរឆ្នាំឡើងស្របតាមផែនការរបស់វិទ្យាស្ថាន និងក្រសួង។

**ប្រការ១២ ._**

ការជ្រើសរើសគ្រូបង្រៀន អប់រំពិសេសផ្នែកពិការភ្នែក គថ្លង់ និងពិការសតិបញ្ញាបន្ថែម និងការជ្រើសរើសចូលធ្វើវិក្រឹតការ ត្រូវស្របតាមកំណើនសិស្ស ហើយមានការឯកភាពពីក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា។

ក្នុងករណីមានផ្ទេរបុគ្គលិកអប់រំចូលទៅបំរើការងារក្នុងគ្រឹះស្ថានសិក្សាអប់រំពិសេស ត្រូវមានយោបល់ឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិន។

**ប្រការ១៣ ._**

ការជ្រើសរើសគ្រូបង្រៀនកិច្ចសន្យាអប់រំពិសេស សម្រាប់បម្រើការនៅគ្រឹះស្ថានសិក្សាអប់រំពិសេស ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងត្រូវមានលក្ខខណ្ឌបន្ថែម ដូចខាងក្រោម៖

- សញ្ញាបត្រកម្រិតមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើឡើង
- មានជំនាញផ្នែកអប់រំពិសេស ដូចជាភាសាសញ្ញា អក្សរប្រេយ៍ (អក្សរស្ទាប) និងផ្នែកសតិបញ្ញា
- មានបទពិសោធការងារជាមួយកុមារមានពិការភាព និងសិស្សមានពិការភាពចម្រុះ



Scanned by CamScanner

- មានចំណេះដឹងផ្នែកអប់រំពិសេស
- មានសញ្ញាបត្រផ្នែកអប់រំពិសេស ឬជំនាញអប់រំកុមារមានពិការភាព
- មានសញ្ញាបត្រគរុកោសល្យ និងជំនាញឯកទេសតាមមុខវិជ្ជា
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឡើងទៅ
- មានទំនាក់ទំនងល្អ រួសរាយរាក់ទាក់
- មានភាពអំណត់ ព្យាយាម លើកទឹកចិត្ត ចូលរួមសកម្មភាពសង្គម
- មានចំណេះដឹងអំពីការប្រើប្រាស់ឧបករណ៍ជំនួយ ការកំណត់អត្តសញ្ញាណកុមារមានពិការភាព
- មានចំណេះដឹងអំពីកម្មវិធីសិក្សា និងប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជា
- មានចំណេះដឹងអំពីការផលិត និងប្រើប្រាស់សម្ភារសិក្សាសម្រាប់សិស្សមានពិការភាព។

**ប្រការ១៤ ._**

ការជ្រើសរើសមន្ត្រីកិច្ចសន្យាសម្រាប់បម្រើការនៅគ្រឹះស្ថានសិក្សាអប់រំពិសេស ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងត្រូវមានលក្ខខណ្ឌបន្ថែមដូចខាងក្រោម៖

- មានជំនាញអប់រំពិសេស ឬជំនាញអប់រំកុមារមានពិការភាព
- មានចំណេះដឹងអំពីការប្រើប្រាស់ឧបករណ៍ជំនួយ ការកំណត់អត្តសញ្ញាណកុមារមានពិការភាព
- មានចំណេះដឹងអំពីការផលិត និងការប្រើប្រាស់សម្ភារសិក្សាសម្រាប់សិស្សមានពិការភាព
- មានទំនាក់ទំនងល្អ រួសរាយរាក់ទាក់
- មានភាពអំណត់ ព្យាយាម លើកទឹកចិត្ត ចូលរួមសកម្មភាពសង្គម។

## ជំពូកទី៥
## ការកំណត់និយាមសិស្សថ្នាក់

**ប្រការ១៥ ._**

សិស្សពិការភ្នែក គថ្លង់ និងសិស្សពិការសតិបញ្ញាមានអាយុចាប់ពី ៣ឆ្នាំ ដល់៥ឆ្នាំ មានសិទ្ធិចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យសិក្សា នៅសាលាអប់រំពិសេស ឬវិទ្យាល័យអប់រំពិសេស។

សិស្សពិការភ្នែក គថ្លង់ និងសិស្សពិការសតិបញ្ញាមានអាយុចាប់ពី ៦ឆ្នាំ ដល់១៤ឆ្នាំ មានសិទ្ធិចុះឈ្មោះចូលរៀនថ្នាក់ទី១ នៅសាលាអប់រំពិសេស ឬវិទ្យាល័យអប់រំពិសេស។

**ប្រការ១៦ ._**

សិស្សពិការភ្នែក គថ្លង់ និងសតិបញ្ញា ត្រូវបានកំណត់និយាម ចាប់ពី៣(បី)នាក់ដល់១០(ដប់)នាក់ក្នុងមួយថ្នាក់ សម្រាប់រៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្មនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ កម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ។ ក្នុងករណីសិស្សមានពិការភាពចំនួន១១នាក់ឡើងទៅត្រូវបំបែកជាពីរថ្នាក់។

សិស្សពិការភ្នែក គថ្លង់ និងសតិបញ្ញា ត្រូវចូលរៀនមួយពេលទៀតនៅគ្រឹះស្ថានសិក្សាសាធារណៈ រហូតបញ្ចប់គ្រប់ភូមិសិក្សា។ សិស្សពិការភ្នែករៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម គិតចាប់ពី



Scanned by CamScanner

ថ្នាក់ទី២ឡើងទៅ សិស្សពិការ គថ្លង់គិតចាប់ពីថ្នាក់ទី៤ឡើងទៅ និងសិស្សពិការសតិបញ្ញាគិតចាប់ពីថ្នាក់ទី១ឡើងទៅ។

**ប្រការ១៧ ._**

គ្រូបង្រៀនពិការភ្នែក និងគថ្លង់ម្នាក់ ត្រូវបង្រៀនមួយថ្នាក់ នៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម ដោយបន្ថែម គ្រូជំនួយម្នាក់ដែលមិនពិការ។

គ្រូបង្រៀនដែលមិនពិការម្នាក់មានជំនាញភាសាសញ្ញា និងអក្សរស្ទាប ត្រូវបង្រៀនមួយថ្នាក់នៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្មដោយមិនមានគ្រូជំនួយ និងត្រូវទៅសម្របសម្រួលមួយថ្នាក់នៅតាមគ្រឹះស្ថានសិក្សាសាធារណៈចាប់ពីកម្រិតបឋមសិក្សាឡើងទៅ។

គ្រូបង្រៀនមិនពិការម្នាក់ដែលមានជំនាញពិការសតិបញ្ញា ត្រូវបង្រៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្មចំនួនមួយថ្នាក់ ដោយមានគ្រូពិការសតិបញ្ញា ឬគ្រូជំនាញពិការសតិបញ្ញាម្នាក់បន្ថែមទៀតជាគ្រូជំនួយ។

**ប្រការ១៨ ._**

និស្សិតពិការភ្នែក គថ្លង់ និងសតិបញ្ញា រៀននៅវិទ្យាស្ថានជាតិអប់រំពិសេស ត្រូវបានកំណត់តាមនិយាម ចាប់ពី៣(បី)នាក់ដល់១០(ដប់)នាក់ ក្នុងមួយថ្នាក់ ។ ក្នុងករណីនិស្សិតមានពិការភាពចំនួន១១ នាក់ឡើងទៅ ត្រូវបំបែកជាពីរថ្នាក់។

គ្រូបង្រៀនពិការភ្នែក និងគថ្លង់ម្នាក់ ត្រូវបង្រៀនមួយថ្នាក់ ដោយបន្ថែមគ្រូមិនពិការម្នាក់ជាគ្រូជំនួយ។ គ្រូបង្រៀនមិនពិការម្នាក់ ត្រូវបង្រៀនមួយថ្នាក់ដោយមិនមានគ្រូជំនួយ។

គ្រូបង្រៀនមិនពិការម្នាក់ដែលមានជំនាញពិការសតិបញ្ញា ត្រូវបង្រៀនមួយថ្នាក់ដោយមានគ្រូពិការសតិបញ្ញាម្នាក់ ឬគ្រូជំនាញពិការសតិបញ្ញាម្នាក់បន្ថែមទៀតជាគ្រូជំនួយ។

## ជំពូកទី៦

## ការផ្តល់បៀវត្សរ៍ឧបត្ថម្ភបន្ថែម

**ប្រការ១៩ ._**

គ្រូបង្រៀនអប់រំពិសេស និងបុគ្គលិករដ្ឋបាលដែលបម្រើការនៅគ្រឹះស្ថានអប់រំពិសេស ត្រូវទទួលបានប្រាក់ឧបត្ថម្ភបន្ថែមប្រចាំខែ លើបៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលស្របតាមការកំណត់របស់រាជរដ្ឋាភិបាល។

គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំពិសេស ត្រូវទទួលបានបៀវត្សតាមរបបកំណត់របស់រដ្ឋ និងត្រូវទទួលបានប្រាក់ឧបត្ថម្ភបន្ថែមដូចគ្រូបង្រៀនអប់រំពិសេសដែរ។

បុគ្គលិកជាប់កិច្ចសន្យា ត្រូវទទួលបានបៀវត្សតាមរបបកំណត់របស់រដ្ឋ និងមិនត្រូវទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែដូចគ្រូបង្រៀនអប់រំពិសេសទេ។

បុគ្គលិកអប់រំពិសេសទាំងអស់ដែលបម្រើការងារនៅគ្រឹះស្ថានអប់រំពិសេស មិនត្រូវទទួលបានរបបឧបត្ថម្ភផ្សេងទៀតដែលកំពុងអនុវត្តនៅក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ដូចជាប្រាក់ឧបត្ថម្ភសម្រាប់ថ្នាក់ពីរវេន ឬថ្នាក់គួប ឬប្រាក់តំបន់ជាដើម។



Scanned by CamScanner

## ជំពូកទី៧
## ការគ្រប់គ្រង ពិនិត្យតាមដាន និងវាយតម្លៃ

**ប្រការ២០ .-**

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអប់រំពិសេស ត្រូវគ្រប់គ្រង ពិនិត្យតាមដាន និងចាត់ចែងសេវាបង្រៀនផ្នែកអប់រំពិសេស ឱ្យមានប្រសិទ្ធភាព ផ្អែកលើភារកិច្ចកំណត់ ភារកិច្ចបន្ថែម និងប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា និងបុគ្គលិកកិច្ចសន្យាអប់រំពិសេស អនុលោមតាមនិយាមកំណត់។

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអប់រំពិសេស ត្រូវគ្រប់គ្រង និងចាត់ចែងការងារ ដោយមានគណនេយ្យភាព និងការទទួលខុសត្រូវផ្ទាល់ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្ត។

**ប្រការ២១ .-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃអំពីស្ថានភាពនៃការគ្រប់គ្រង និងការចាត់ចែងការបង្រៀននៅក្នុងគ្រឹះស្ថានសិក្សាអប់រំពិសេស នៅរៀងរាល់ដំណាច់ឆ្នាំសិក្សានីមួយៗ ឬផ្អែកលើភាពចាំបាច់នៃការងារក្នុងគោលដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្ស គាំទ្រដល់សេវាបង្រៀនផ្នែកអប់រំពិសេស។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ២២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២៣ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២៣
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ នា .នីតិកម្ម



Scanned by CamScanner